# សកម្មភាពបន្ទាន់១០ចំណុចក្នុងផ្នែកទឹកស្អាតនិងអនាម័យតាមសាលារៀន

## សម្រាប់នាយកសាលាឆ្លើយតបនឹងជំងឺកូវីដ១៩ (COVID-19)

### ១ ការលាងសម្អាតដៃ

រៀបចំបរិក្ខារលាងសម្អាតដៃជាមួយសាប៊ូតាមច្រកចូលសាលារៀន (បរិក្ខារប្រើជើងជាន់បង្ហូរទឹក ធុងបង្ហូរទឹក បរិក្ខារលាងសម្អាតដៃជាក្រុម) ដោយមានចំនួនរ៉ូប៊ីណេគ្រប់គ្រាន់ក្នុងការរក្សាគម្លាតសុវត្ថិភាពដល់សិស្ស បុគ្គលិកសាលា និងសាធារណៈជន អាចលាងសម្អាតដៃមុនចូលបរិវេណសាលារៀន។ ត្រូវប្រាកដថាបង្គន់អនាម័យមានបរិក្ខារលាងសម្អាតដៃដែលអាចប្រើប្រាស់បានជាមួយសាប៊ូនិងទឹក។

### ២ មានទឹកប្រើប្រាស់

ធានាថាមានទឹកសម្រាប់លាងសម្អាតដៃ ទទួលទាន និងប្រើប្រាស់ផ្សេងៗទៀត។ ករណីការផ្គត់ផ្គង់ទឹកក្នុងសាលារៀនមិនទៀងទាត់ឬមិនគ្រប់គ្រាន់ ត្រូវបង្កើនសមត្ថភាពស្តុកទឹកបន្ថែមដោយសុំជំនួយគាំទ្រពីសហគមន៍ ឬប្រាប់សិស្សឱ្យយកទឹកពីផ្ទះម្នាក់មួយដបៗប្រសិនបើអាច។

### ៣ ការផ្គត់ផ្គង់ផ្សេងៗ

គណនាពីតម្រូវការនិងធានាការផ្គត់ផ្គង់ឱ្យបានគ្រប់គ្រាន់នូវសម្ភារអនាម័យរួមមាន៖ សាប៊ូ (ជាដុំឬទឹក) ដែលលាងសម្អាតដៃ (មានកំហាប់អាល់កុលយ៉ាងតិច៧០ភាគរយ ផ្អែកតាមបរិបទជាក់ស្តែង)និងសូជ្យូមអ៊ីប៉ូក្លរីតសម្រាប់លាងសម្អាតឬរម្ងាប់មេរោគ (សារធាតុគីមីធ្វើឱ្យសប្រើតាមផ្ទះដែលត្រូវបានពង្រាវឱ្យសល់កំហាប់ត្រឹម០.១%) អេប៉ុងជក់ទឹក អំបោស ធុងទឹក និងឧបករណ៍ការពារដូចជាម៉ាសនិងស្រោមដៃសម្រាប់អ្នកអនាម័យជាដើម។ សូលុយស្យុងរម្ងាប់មេរោគដែលមានកំហាប់អាល់កុលយ៉ាងតិច៧០ភាគរយអាចប្រើជំនួសសារធាតុគីមីធ្វើឱ្យសប្រើតាមផ្ទះបាន។

### ៤ ការសម្អាតនិងរម្ងាប់មេរោគ

ធានាថាមានការសម្អាតនិងរម្ងាប់មេរោគជាប្រចាំតាមគោលការណ៍ណែនាំរបស់រដ្ឋាភិបាលនិងអនុសាសន៍ជាសកលផ្សេងៗ។ រាល់ផ្ទៃដែលមានការប៉ះពាល់ញឹកញាប់គួរកំណត់ជាអាទិភាពសម្រាប់រម្ងាប់មេរោគ។ មុនធ្វើសកម្មភាពរម្ងាប់មេរោគ ត្រូវលាងរាល់ផ្ទៃដែលត្រូវសម្អាតជាមួយសាប៊ូឬម្សៅសាប៊ូនឹងទឹក ដើម្បីកម្ចាត់សារធាតុសរីរាង្គជាមុនសិន។ គណនារយៈពេលដែលត្រូវធ្វើ និងធានាថាមានបុគ្គលិកទទួលបន្ទុកអនាម័យអនុវត្តការសម្អាត និងរម្ងាប់មេរោគដោយពាក់ម៉ាស នឹងស្រោមដៃ។ រៀបចំឱ្យមានការចូលរួមពីសមាគមមាតាបិតាគ្រូ សហគមន៍ និងសិស្សជាចាំបាច់ ដើម្បីសម្អាតសាលារៀនទាំងអស់គ្នា។ ធានាថាកន្លែងលាងសម្អាតដៃ និងបង្គន់អនាម័យអាចប្រើប្រាស់បាននិងស្អាតជានិច្ច។

### ៥ ការគ្រប់គ្រងសំរាម

ត្រូវធានាថាមានធុងសំរាមនៅក្នុងថ្នាក់រៀន ក្នុងបង្គន់អនាម័យ និងមានតាមទីតាំងសំខាន់ៗនៃបរិវេណសាលារៀន ហើយត្រូវយកសំរាមចាក់ចោលជារៀងរាល់ថ្ងៃប្រកបដោយសុវត្ថិភាពតាមប្រព័ន្ធគ្រប់គ្រងសំរាម។

### ៦ ការរក្សាគម្លាតសុវត្ថិភាព

ត្រូវប្រាកដថាកុមារនិងបុគ្គលិកសាលា ប្រកាន់ខ្ជាប់នូវគម្លាតសុវត្ថិភាពយ៉ាងតិច១ម៉ែត្រពីគ្នា (ឬតាមគោលការណ៍ណែនាំថ្នាក់ជាតិ)។ ជម្រើសដែលអាចធ្វើទៅបានមានដូចជា៖ បែងចែកកុមារឱ្យរៀនក្នុងវេនខុសគ្នា រៀបចំឱ្យសិស្សចូលរៀន ចេញលេង និងចេញទៅផ្ទះនៅម៉ោងខុសគ្នា រៀបចំតុរៀនឱ្យមានគម្លាតពីគ្នា បង្រៀននៅក្រៅថ្នាក់ឬបង្រៀនដោយបើកបង្អួចឱ្យមានខ្យល់ចេញចូល (បើអាចអនុវត្តបាន) និងរៀបចំកន្លែងអង្គុយឬឈរឱ្យមានគម្លាតសមស្រប បិតស្កុតឬគូសខ្សែបន្ទាត់ខណ្ឌចែកនៅកន្លែងក្មេងតម្រង់ជួរឬប្រមូលផ្តុំ (ឧទាហរណ៍នៅមុខបង្គន់អនាម័យ ឬបរិក្ខារលាងសម្អាតដៃ)។

### ៧ បង្កើតក្រុមត្រួតពិនិត្យ

ចាត់តាំងសមាជិកក្រុមការងារដូចជា លោកគ្រូ អ្នកគ្រូ  អ្នកបោសសម្អាត សន្តិសុខ អ្នកថែសួន សិស្សពេញវ័យ សមាជិកសហគមន៍ និងក្លឹបទឹកស្អាតអនាម័យជាដើម ដើម្បីត្រួតពិនិត្យកន្លែងលាងសម្អាតដៃ និងបង្គន់អនាម័យ (ដោយផ្តោតលើទឹកនិងសាប៊ូ  ការថែទាំ ឥរិយាបថនៃការលាងសម្អាតដៃ និងការអនុវត្តតាមគោលការណ៍នៃគម្លាតសុវត្ថិភាព។ល។) ។

### ៨ ការតម្រង់ទិស/ បណ្តុះបណ្តាល

រៀបចំការតម្រង់ទិសដល់លោកគ្រូ អ្នកគ្រូ និងបុគ្គលិកសាលា ព្រមទាំងសមាជិកសហគមន៍ទាំងអស់ឱ្យបានយល់ពីកម្មវិធីទឹកស្អាតនិងអនាម័យតាមសាលារៀននិងជំងឺកូវីដ១៩ ហើយត្រូវធានាថាពួកគេបានដឹងពីតួនាទីនិងការទទួលខុសត្រូវរៀងៗខ្លួន។ ធានាថាលោកគ្រូ អ្នកគ្រូបន្តតម្រង់ទិសដល់អ្នកសិក្សាដោយប្រើសម្ភារផ្សព្វផ្សាយស្តីពីអនាម័យស្របតាមវ័យរបស់ពួកគេ។

### ៩ បញ្ជីត្រួតពិនិត្យ

ណែនាំពីការប្រើប្រាស់បញ្ជីត្រួតពិនិត្យ (រួមមាន៖ កាលបរិច្ឆេទ ពេលវេលាត្រួតពិនិត្យ និងឈ្មោះអ្នកទទួលខុសត្រូវ) ដល់លោកគ្រូ អ្នកគ្រូ និងបុគ្គលិកសាលា ហើយត្រូវធានាថាពួកគេអនុវត្តវាជាប្រចាំដើម្បីក្លាយជាទម្លាប់ប្រចាំថ្ងៃក្នុងការត្រួតពិនិត្យសាលារៀន។ បញ្ជីត្រួតពិនិត្យគួរផ្តោតលើ៖

- ច្រកចូលសាលារៀន (ឥរិយាបថនៃការលាងសម្អាតដៃ កន្លែងលាងសម្អាតដៃ វត្តមានទឹកនិងសាប៊ូ)
- ថ្នាក់រៀន (សេចក្តីណែនាំស្តីពីការសម្អាតនិងរម្ងាប់មេរោគ)
- បង្គន់អនាម័យនិងការគ្រប់គ្រងសំរាម

### ១០ វប្បធម៌នៃការរក្សាអនាម័យ

បង្កើតវប្បធម៌នៃការរក្សាអនាម័យតាមសាលារៀន និងលើកទឹកចិត្តឱ្យមានការផ្លាស់ប្តូរឥរិយាបថរក្សាអនាម័យក្នុងសហគមន៍។ ត្រូវបញ្ជាក់ឱ្យបានច្បាស់ថា លោកគ្រូ អ្នកគ្រូ និងបុគ្គលិកសាលាគ្រប់រូប គឺជាផ្នែកមួយនៃក្រុមការងារ ត្រៀមបង្ការនិងឆ្លើយតបជំងឺរាតត្បាត ហើយធានាថាការសិក្សានៅតែអាចបន្តទៅមុខជាមួយនឹងសាលារៀនស្អាតនិងប្រកបដោយសុវត្ថិភាព។ ត្រូវទទួលស្គាល់និងឱ្យតម្លៃដល់អ្នកគាំទ្រកម្មវិធីទឹកស្អាតនិងអនាម័យតាមសាលារៀននិងសហគមន៍។

ទំនាក់ទំនង៖ WinS-COVID-19@susana.org

ព័ត៌មានបន្ថែម៖ www.susana.org

- "សកម្មភាពបន្ទាន់១០ចំណុចក្នុងផ្នែកទឹកស្អាតនិងអនាម័យតាមសាលារៀន" (កែតម្រូវចុងក្រោយ)៖ https://bit.ly/367F7ur
- ផែនទីចង្អុលឯកសារពាក់ព័ន្ធ "ទឹកស្អាតនិងអនាម័យតាមសាលារៀន និងគូរ៉ូណាវីរុស"៖ https://bit.ly/2JDvM39
- "ការបើកសាលារៀនឡើងវិញដោយសុវត្ថិភាព៖ សៀវភៅមគ្គុទ្ទេសក៍អនុវត្ត"៖ https://bit.ly/2zS3UHr



german cooperation DEUTSCHE ZUSAMMENARBEIT | giz Deutsche Gesellschaft für Internationale Zusammenarbeit (GIZ) GmbH | unicef | Save the Children | WaterAid

៧ កក្កដា ២០២០// បណ្តាញក្រុមការងារទឹកស្អាតនិងអនាម័យតាមសាលារៀន (GIZ, UNICEF, Save the Children, WaterAid និងអង្គការផ្សេងៗទៀត) គឺជាបណ្តាញទីភ្នាក់ងារអន្តរជាតិដែលមានសមាជិកជាង៦០អង្គការចូលរួមអនុវត្តកម្មវិធីទឹកស្អាតនិងអនាម័យតាមសាលារៀន។

CC BY NC ND